ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ......✓..........

# សេចក្តីជូនដំណឹង

អ្នកនាំពាក្យក្រសួងការពារជាតិ សូមជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សាធារណជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ឱ្យបានជ្រាបថា យោងទៅតាមសំណើមជ្ឈមណ្ឌលជាតិ និងចំណារ សម្តេចពិជ័យសេនា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៨ កម្មវិធីទទួលដំណើរមាតុភូមិនិវត្តន៍ កងកម្លាំងរក្សាសន្តិភាពអ.ស.បរបស់កម្ពុជា រួមមាន កងវិស្វកម្ម លេខ៩៥៤ ចំនួន២១៦នាក់ ពីសាធាណរដ្ឋអាហ្វ្រិកកណ្តាល និងកងរាជអាវុធហត្ថលេខ៦១៨ ចំនួន៧៣នាក់ ពីសាធារណរដ្ឋស៊ូដង់ខាងត្បូង ក្រោមអធិបតីភាព សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅមូលដ្ឋានទ័ពអាកាសពោធិចិនតុង ដែលគ្រោងធ្វើឡើង នៅរសៀលថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៨នោះ ត្រូវបានប្តូរទៅ ម៉ោង៨:០០នាទី ព្រឹកថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ វិញ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកសារព័ត៌មានជាតិ-អន្តរជាតិ ជ្រាបជាព័ត៌មាន៕

ថ្ងៃព្រហស្បត្តិ៍ ៨រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨